Australian Government

Department of Agriculture, Fisheries and Forestry




សេវាប្រមូលពន្ធរដ្ឋ (LRS) គឺជាផ្នែកនៃក្រសួងកសិកម្ម ជលផល និងរុក្ខាប្រមាញ់។
យើងទទួលបន្ទុកក្នុងការប្រមូល គ្រប់គ្រងចាត់ចែង ហើយចែកចាយពន្ធដែលប្រមូលបានក្នុងនាមឧស្សាហកម្ម។

# តើលោកអ្នកត្រូវបង់ ឬប្រមូលពន្ធ / បង់ពន្ធលើទំនិញនាំចេញក្រៅប្រទេស លើផលិតផលដំណាំឬទេ?

ពន្ធ / ពន្ធលើទំនិញនាំចេញក្រៅប្រទេស ជាពន្ធបង់លើផលិតផលដំណាំមួយចំនួនដើម្បីផ្គត់ផ្គង់ថវិកាដល់អង្គការឧស្សាហកម្មដែលទាក់ទិន គឺក្រុមហ៊ុនដំណាំអូស្ត្រាលី (Horticulture Australia Limited) (HAL) សំរាប់សកម្មភាពស្រាវជ្រាវ អភិវឌ្ឍន៍ និងការផ្សព្វផ្សាយផលិតផល។ ផលិតផលខ្លះមានដាក់នូវសមាសភាគមួយផងដែរដើម្បីឧបត្ថម្ភប្រាក់សំរាប់កម្មវិធីធ្វើតេស្តលើកាកសំណល់ជាតិថ្នាំគីមី ដែលចាត់ចែងឡើងដោយអាជ្ញាធរវាស់ស្ទង់ជាតិ លើកាកសំណល់ជាតិថ្នាំគីមី (National Residue Survey) (NRS) និងកម្មវិធីសុខភាពរុក្ខជាតិតាមរយៈ សុខភាពរុក្ខជាតិអូស្ត្រាលី (Plant Health Australia) (PHA)។

អ្នកផលិតត្រូវទទួលខុសត្រូវចំពោះការបង់ពន្ធ។ ពេលណាអ្នកផលិតលក់ផលិតផលរបស់ខ្លួនតាមរយៈឈ្មួញកណ្តាល ដូចជាអ្នកទិញដំបូង ភ្នាក់ងារទិញ ភ្នាក់ងារលក់ ឈ្មួញលក់ដុំ ឬអ្នកសំរេចការក្នុងការផលិត នុះឈ្មួញកណ្តាលត្រូវទទួលខុសត្រូវចំពោះការបង់ពន្ធជំនួសអ្នកផលិត។ ឈ្មួញកណ្តាលត្រូវបញ្ជូនបន្តពន្ធជាមួយនឹងហ្វ៍មបញ្ជូនត្រឡប់ទៅឲ្យ LRS។ ឈ្មួញកណ្តាលអាចទាមទារពន្ធដែលខ្លួនបានបង់ពីអ្នកផលិតវិញ ដោយធ្វើការទូទាត់ ឬធ្វើផ្សេងពីនេះ។ លោកអ្នកអាចទទួលយកហ្វ៍មបញ្ជូនបន្តពន្ធ ឬព័ត៌មានបន្ថែមទៀតបានពីគ្រប់ការិយាល័យ LRS ឬបើកមើលវ៉ិបសាយរបស់យើងនៅត្រង់ www.daff.gov.au/levies។

អ្នកផលិតដែលលក់ផលិតផលដំណាំតាមបែបលក់រាយ ពោលគឺលក់ផ្ទាល់ទៅឲ្យអតិថិជន ដូចជាលក់តាមរានលក់នៅតាមដងផ្លូវ តូបលក់ ឬមាត់ផ្លូវចូលទៅចំការ នុះគេត្រូវដាក់ពាក្យសុំបង់ពន្ធ រួចបញ្ជូនត្រឡប់ទៅឲ្យ LRS ផ្ទាល់។ មានការលើកលែងខ្លះៗអាចអនុវត្តចំពោះការលក់រាយ។

នៅក្នុងករណីនៃការបង់ពន្ធលើទំនិញនាំចេញក្រៅប្រទេស អ្នកផលិតត្រូវបានឲ្យអត្ថន័យថាជាជនដែលលក់ចេញនូវផលិតផលពីប្រទេសអូស្ត្រាលី (ដែលត្រូវជាម្ចាស់នៃផលិតផលនៅពេលលក់ចេញក្រៅប្រទេស) ត្រូវទទួលខុសត្រូវចំពោះការបង់ពន្ធ។ ជននេះត្រូវតែបញ្ជូនបន្តពន្ធលើទំនិញនាំចេញក្រៅប្រទេស ដោយភ្ជាប់ជាមួយនឹងហ្វ៍មបញ្ជូនត្រឡប់ទៅឲ្យ LRS។ ប្រសិនបើផលិតផលបាននាំចេញក្រៅប្រទេសតាមរយៈភ្នាក់ងារនាំទំនិញចេញក្រៅប្រទេស ភ្នាក់ងារនេះត្រូវទទួលខុសត្រូវលើការបង់ពន្ធជំនួសអ្នកផលិត ហើយត្រូវដាក់ពាក្យបង់ពន្ធ ជាមួយនឹងហ្វ៍មបញ្ជូនត្រឡប់ទៅឲ្យ LRS។ ភ្នាក់ងារនាំទំនិញចេញក្រៅប្រទេសអាចទាមទារពន្ធនេះមកវិញពីអ្នកផលិត។ ពន្ធលើទំនិញនាំចេញមិនត្រូវបង់ឡើយ ប្រសិនបើពន្ធនោះត្រូវបានគេបង់រួចហើយលើផលិតផលដែលនាំចេញក្រៅប្រទេស។

ចំពោះផលិតផលខ្លះ ឈ្មួញកណ្តាលលក់ផលិតផលដែលគេធ្លាប់យកទៅផលិតជាផលិតផលដែលអាចបង់ពន្ធ។ នៅក្នុងករណីនេះ ឈ្មួញកណ្តាលត្រូវតែប្រមូលពន្ធពីអ្នកផលិត ហើយបញ្ជូនបន្តពន្ធនោះជាមួយនឹងហ្វ៍មបញ្ជូនត្រឡប់ទៅឲ្យ LRS។

ពន្ធ / ពន្ធលើទំនិញនាំចេញក្រៅប្រទេសត្រូវបង់សំរាប់ផលិតផលដំណាំផ្សេងៗពីគ្នា ដូចជាផ្សិត agaricus, គ្រាប់រុក្ខជាតិអាល់មឺន (almonds), ផ្លែប៉ោម ផ្លែអាវ៉ូខាដូ ផ្លែឈៃរី គ្រាប់ឆេស្តណាត់ (chestnuts), ផ្លែក្រូចឆ្មារ ផ្លែទៀប ត្រណាប់ផ្លែឈើ ផ្លែគូលែន គ្រាប់រុក្ខជាតិម៉ាកាដេមៀ (macadamia), ផ្លែស្វាយ កូនរុក្ខជាតិ ខ្ទឹមបារាំង ផ្លែល្ហុង ផ្លែផាស្សិនហ្វ្រ៊ូត (passionfruit), ផ្លែភែ (មានរួមទាំងផ្លែណាហ្ស៊ី nashi) ផ្លែភើស៊ីមឺន (persimmons), ដំឡូងបារាំង ផ្លែឈើមានគ្រាប់ធំៗ ផ្លែស្ត្របឺរី (strawberries), ផ្លែទំពាំងបាយជូរ (table grapes) និងបន្លែ។

ភាពញឹកញាប់នៃការដាក់ពាក្យបង់ពន្ធ / ពន្ធលើទំនិញនាំចេញក្រៅប្រទេស និងហ្វ៍មបញ្ជូនគឺប្រែប្រួលពីផលិតផលមួយ ទៅផលិតផលមួយដែលមានចាប់ពីប្រចាំខែ ទៅរៀងរាល់បីខែម្តង និងមួយឆ្នាំម្តង។

នេះគឺជាសេចក្តីតម្រូវតាមច្បាប់ដែលអ្នកបង់ពន្ធត្រូវរក្សាកំណត់ត្រាដែលខ្លួនបានបង់រួចសំរាប់រយៈពេលប្រាំ(៥)ឆ្នាំ។ កំណត់ត្រាទាំងនេះត្រូវមានសំរាប់ភ្នាក់ងារ LRS ពេលណាមានការស្នើសុំដើម្បីត្រួតពិនិត្យមើល។

# តើពន្ធនាំចេញនេះត្រូវបានគេចាត់ចែងទៅកន្លែងណាខ្លះ?

សេវាប្រមូលពន្ធរដ្ឋ (LRS) ទទួលពន្ធ / ពន្ធលើទំនិញនាំចេញក្រៅប្រទេស ហើយបញ្ជូនបន្តទៅឲ្យ HAL, PHA និង NRS ជាប្រាក់បន្ថែមពីលើប្រាក់ចែកចាយស៊ីគ្នារបស់រដ្ឋាភិបាលអូស្ត្រាលីសំរាប់ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ (R&D)។ ពន្ធ / ពន្ធលើទំនិញនាំចេញក្រៅប្រទេសត្រូវបានណែនាំ ហើយគ្រប់គ្រងដោយរដ្ឋាភិបាលអូស្ត្រាលីស្របទៅតាមការស្នើសុំរបស់ឧស្សាហកម្ម។

ក្រុមហ៊ុន Horticulture Australia Limited (HAL) គឺជាអង្គការមួយដែលមានគោលដៅដើម្បីអភិវឌ្ឍដំណាំអូស្ត្រាលី ដោយផ្តល់នូវកិច្ចបំរើ R&D ធំទូលាយ ហើយប្រកបដោយវិជ្ជាជីវៈ និងពាណិជ្ជកម្មដល់អង្គការលើសពី៣០ខុសៗគ្នា ចាប់ពីឧស្សាហកម្មផ្លែឈើ បន្លែ និងរុក្ខជាតិ។ HAL បានបង្កើតឡើងនៅក្នុងខែកុម្ភៈ ឆ្នាំ២០០១ ពីអតីតសាជីវកម្មស្រាវជ្រាវ និងអភិវឌ្ឍន៍ដំណាំ (Horticultural Research & Development Corporation) (HRDC) និងសាជីវកម្មដំណាំអូស្ត្រាលី (Australian Horticultural Corporation) (AHC)។ HAL គឺជាក្រុមហ៊ុនមួយដែលមានឧស្សាហកម្មជាម្ចាស់ ហើយដែលរដ្ឋាភិបាលអូស្ត្រាលីបានភ្ជាប់កិច្ចសន្យាឲ្យចាត់ចែងកិច្ចបំរើផ្នែកពាណិជ្ជកម្ម និង R&D សំរាប់ឧស្សាហកម្មដំណាំ។ ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀតអំពី HAL លោកអ្នកអាចបើកមើលវ៉ិបសាយរបស់គេនៅត្រង់: www.horticulture.com.au។

National Residue Survey ប្រើប្រាស់ពន្ធដើម្បីពិនិត្យឃ្លាំមើល វាយតម្លៃ ហើយធ្វើរបាយការណ៍អំពីកំរិតនៃកាកសំណល់ជាតិថ្នាំគីមីមាននៅក្នុងម្ហូបអាហារដែលផលិតដោយឧស្សាហកម្មកសិកម្ម និងជលផលដែលបានចូលរួមនៅក្នុងគ្រោងការ។ ការនេះផ្តល់ដល់អតិថិជនក្នុងប្រទេស និងអន្តរជាតិនូវការទុកចិត្តដល់គុណភាព និងសុវត្ថិភាពនៃផលិតផលរបស់ខ្លួន។ ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀតអំពីសកម្មភាពវាស់ស្ទង់មើលកាកសំណល់ជាតិថ្នាំគីមី សូមទាក់ទងជាមួយ National Residue Survey នៅត្រង់វ៉ិបសាយ: www.daff.gov.au/nrs ឬផ្ញើអ៊ីម៉េល: nrs@daff.gov.au។

Plant Health Australia (PHA) គឺជាអង្គការកំពូលដែលទទួលខុសត្រូវចំពោះកិច្ចការជាមួយសមាជិករបស់ខ្លួនដើម្បីគ្រប់គ្រងគ្រោងការ ហើយសម្របសម្រួលចាត់ចែងការអភិវឌ្ឍន៍នៃគោលការណ៍ និងសមត្ថភាពសុខភាពរុក្ខជាតិក្នុងប្រទេសអូស្ត្រាលី។ PHA បានបង្កើតឡើងដោយមានការទទួលស្គាល់ថា ក្នុងអត្តន័យសាកល ប្រទេសអូស្ត្រាលីមានភ័ព្វវាសនាដោយប្រៀបធៀបទៅថាមានបទពិសោធន៍រួចផុតពីសត្វល្អិតចង្រៃ រុក្ខជាតិតូចៗឥតប្រយោជន៍ និងជម្ងឺទាំងឡាយដែលអាចប៉ះពាល់ដល់ឧស្សាហកម្មរុក្ខជាតិ។ PHA កំពុងធ្វើការដើម្បីបង្កើតនូវទស្សនៈប្រើប្រាស់ជាមួយគ្នា និងការទាក់ទង ហើយការយល់ដឹងនូវប្រព័ន្ធគ្រប់គ្រងសុខភាពរុក្ខជាតិមួយដែលកាន់តែមានការសម្របសម្រួល ហើយមានប្រសិទ្ធិភាពជាង។ ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀតអំពី PHA លោកអ្នកអាចបើកមើលវ៉ិបសាយរបស់គេនៅត្រង់: www.planthealthaustralia.com.au។

# របៀបទាក់ទងជាមួយសេវាប្រមូលពន្ធរដ្ឋ

ប្រសិនបើលោកអ្នកចង់ទទួលព័ត៌មានបន្ថែមទៀត សូមទាក់ទងជាមួយយើងតាមអាសយដ្ឋានណាមួយខាងក្រោមនេះ:

| | |
|---|---|
| **រដ្ឋឃ្វីនស្លែន (Queensland)**<br>☎ ទូរស័ព្ទ 1800 647 801<br>ទូរសារ 07 3831 4324 | **រដ្ឋវិចតូរីយ៉ា និងថេស្មានីយ៉ា (Tasmania)**<br>☎ ទូរស័ព្ទ 1800 683 839<br>ទូរសារ 03 9322 5500 |
| **រដ្ឋញូវសៅវែល / ACT**<br>☎ ទូរស័ព្ទ 1800 625 103<br>ទូរសារ 02 9325 6677 | **រដ្ឋអូស្ត្រាលីខាងត្បូង និងដែនដី**<br>☎ ទូរស័ព្ទ 1800 814 961<br>ទូរសារ 08 8201 6099 |
| **រដ្ឋអូស្ត្រាលីខាងលិច**<br>☎ ទូរស័ព្ទ 1800 895 506<br>ទូរសារ 08 9334 1677 | **ទីស្នាក់ការកណ្តាល – ឃែនបេរ៉ា (Canberra)**<br>☎ ទូរស័ព្ទ 1800 020 619<br>ទូរសារ 02 6272 5695 |
| **អ៊ីម៉េលមកយើងតាមអាសយដ្ឋាន:**<br>Levies.Management@daff.gov.au | **បើកមើលនៅត្រង់គេហទំព័ររបស់យើង:**<br>www.daff.gov.au/levies |